No. 22
15.6.97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ២២ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

LAW.

Kimbo

ក

មាតិកា

I. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

០៩.៦.១៩៩៧	អនុក្រឹត្យលេខ ២២ អនក្រ.បក ស្ដីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈសំរាប់ទិញដែកបេតុង និងគ្រឿងចក្រសាងសង់ផ្លូវ	១២៦៨
០៩.៦.១៩៩៧	អនុក្រឹត្យលេខ ២៣ អនក្រ.បក ស្ដីពីការប្រើប្រាស់គណនី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ សំរាប់ជួសជុលស្នាក់ការគណៈកម្មាធិការអន្តរជាតិទន្លេមេគង្គ	១២៧០
០៩.៦.១៩៩៧	អនុក្រឹត្យលេខ ២៤ អនក្រ.បកស្ដីពីការបង្កើតគណកម្មការជាតិ អេស្កាប់	១២៧១
១០.៦.១៩៩៧	អនុក្រឹត្យលេខ ២៥ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មាធិការ សំរាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	១២៧៥
១២.៦.១៩៩៧	អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្ដីពីការកំណត់ឡើងវិញនូវព្រំប្រទល់រដ្ឋបាលក្រុងកែប បន្ថែមជាមួយខេត្តកំពត ត្រង់ចំណុចចំការបី	១២៧៧
០៩.៦.១៩៩៧	អនុក្រឹត្យលេខ ៥៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ	១២៧៩
១២.៦.១៩៩៧	អនុក្រឹត្យលេខ ៥៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១២៨[illegible]
១២.៦.១៩៩៧	អនុក្រឹត្យលេខ ៥៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១២៨២
១២.៦.១៩៩៧	អនុក្រឹត្យលេខ ៥៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១២៨៣

២. សារាចរ

១២.៦.១៩៩៧	សារាចរលេខ ០៣ សរ ស្ដីពីបែបបទ និងនីតិវិធីនៃការស្នើសុំរួចពន្ធឧបករណ៍ សំភារៈនាំចូល ក្នុងក្របខ័ណ្ឌជំនួយឥតសំណងឥណទាន និងជំនួយមនុស្សធម៌	១២៨៤

II. ការងារបណ្ដាក្រសួង

១. ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

០៩.៦.១៩៩៧	ប្រកាសលេខ ៥៤៣ ផក.ប្រក អនុញ្ញាតឱ្យលោក ហាំង វេង ជនជាតិ	

	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរកា[illegible]ងជាងផលិតប៉ោតធុង	១២៨៦
០៩.៦.១៩៩៧	ប្រកាសលេខ ៥៤៤ ផក.ប្រក អនុញ្ញាតឱ្យលោក សែម ចាន់តា ជនជាតិ	
	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងជុសជុលរថយន្ត	១២៨៦
០៩.៦.១៩៩៧	ប្រកាសលេខ ៥៤៥ ផក.ប្រក អនុញ្ញាតឱ្យលោក ម៉ែន សារុធ ជនជាតិ	
	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងជួសជុល ប៊ុមអាំង	
	ហ្សិចស្បុងរថយន្ត	១២៨៧
០៩.៦.១៩៩៧	ប្រកាសលេខ ៥៤៦ ផក.ប្រក អនុញ្ញាតឱ្យអ្នកស្រី ទីវ ហេង ជនជាតិ	
	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិត ឥដ្ឋ-ក្បឿង	១២៨៧
០៩.៦.១៩៩៧	ប្រកាសលេខ ៥៤៧ ផក.ប្រក អនុញ្ញាតឱ្យអ្នកស្រី កែវ ហ៊ុ ជនជាតិ	
	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិត ឥដ្ឋ-ក្បឿង	១២៨៨
១០.៦.១៩៩៧	ប្រកាសលេខ ៥៤៩ ផក.ប្រក អនុញ្ញាតឱ្យលោក ច័ន្ទ កុសល ជនជាតិ	
	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតស្រា កែច្នៃ	
	យីហោ "លី ហ៊ុយតឹង"	១២៨៨
១០.៦.១៩៩៧	ប្រកាសលេខ ៥៥០ ផក.ប្រក អនុញ្ញាតឱ្យលោក វុន កុយ ជនជាតិ	
	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងមាស៊ីនកិនស្រូវកំលាំង២០សេះ	១២៨៩
១០.៦.១៩៩៧	ប្រកាសលេខ ៥៥១ ផក.ប្រក អនុញ្ញាតឱ្យលោក ភូ សុខឃៀប ជនជាតិ	
	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៨០សេះ	១២៨៩
១០.៦.១១៩៧	ប្រកាសលេខ ៥៥២ ផក.ប្រក អនុញ្ញាតឱ្យលោក ឆឹយ សារ៉េន ជនជាតិ	
	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	១២៩០
១[illegible].៦.១៩៩៧	ប្រកាសលេខ ៥៥៣ ផក.ប្រក អនុញ្ញាតឱ្យលោក គុណេ ប៊ុនរិទ្ធិ ជនជាតិ	
	ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មដេរពូកឡាន-ម៉ូតូ	១២៩១
[illegible].៦.១៩៩៧	ប្រកាសលេខ ៥៥៥ បល.ប្រក បង្កើតការិយាល័យអភិវឌ្ឍន៍តំបន់	
	ឧស្សាហកម្ម	១២៩១
[illegible].៦.១១៩៧	ប្រកាសលេខ ៥៥៦ បល.ប្រក បង្កើតការិយាល័យកម្មសិទ្ធិឧស្សាហកម្ម	១២៩២
[illegible]១៩៩៧	ប្រកាសលេខ ៥៥៧ បល.ប្រក បង្កើតការិយាល័យស្តង់ដាឧស្សាហកម្ម	១២៩៣

១២.៦.១៩៩៧	[illegible]ាសលេខ ៥៦៨ ផក.ប្រក អនុញ្ញាតឱ្យលោក សុខ សន ជនជាតិ [illegible] សញ្ជាតិកម្ពុជា បើកសិប្បកម្មផលិត[illegible] កែច្នៃ	១២៩៤
១២.៦.១៩៩៧	ប្រកាសលេខ ៥៦៩ ផក.ប្រក អនុញ្ញាតឱ្យលោក ឡា អន ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មកែច្នៃឈើ	១២៩៥
១២.៦.១៩៩៧	ប្រកាសលេខ ៥៧០ ផក.ប្រក អនុញ្ញាតឱ្យលោក អ៊ឹង គីមលី ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានសិប្បកម្មផលិត ឥដ្ឋ-ក្បឿងផ្ទេរការកិច្ច គ្រប់គ្រងជូនលោក លី មាន វិញ	១២៩៦
១២.៦.១៩៩៧	ប្រកាសលេខ ៥៧១ ផក.ប្រក អនុញ្ញាតឱ្យលោក ហ៊ីង ស៊ីវ៉ា ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង១២០សេះ	១២៩៦
១២.៦.១៩៩៧	ប្រកាសលេខ ៥៧២ ផក.ប្រក អនុញ្ញាតឱ្យលោក លី សារ៉ាត់ ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៧៧សេះ	១២៩៧
១២.៦.១៩៩៧	ប្រកាសលេខ ៥៧៣ ផក.ប្រក អនុញ្ញាតឱ្យលោក រស់ រីន ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើការរោងម៉ាស៊ីនកិនស្រូវកំលាំង១២០សេះ	១២៩៧
១២.៦.១៩៩៧	ប្រកាសលេខ ៥៧៤ ផក.ប្រក អនុញ្ញាតឱ្យលោក ឌុច ជំនិត ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៦០សេះ	១២៩៨
១២.៦.១៩៩៧	ប្រកាសលេខ ៥៧៥ ផក.ប្រក អនុញ្ញាតឱ្យលោក លី ហុកហាន់ ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង៣៥សេះ	១២៩៩
១២.៦.១៩៩៧	ប្រកាសលេខ ៥៧៦ ផក.ប្រក អនុញ្ញាតឱ្យលោក ម៉េង តា ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	១២៩៩
១២.៦.១៩៩៧	ប្រកាសលេខ ៥៧៧ ផក.ប្រក អនុញ្ញាតឱ្យលោក និ ជុច ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតនំប៉័ង	១៣០០
១២.៦.១៩៩៧	ប្រកាសលេខ ៥៧៨ ផក.ប្រក អនុញ្ញាតឱ្យលោក ថាច់ គង់មី ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋ-ក្បឿង	១៣០០
១២.៦.១៩៩៧	ប្រកាសលេខ ៥៧៩ ផក.ប្រក អនុញ្ញាតឱ្យលោក ជន់ ហួរ ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋ-ក្បឿង	១៣០១
១២.៦.១៩៩៧	ប្រកាសលេខ ៥៨០ ផក.ប្រក អនុញ្ញាតឱ្យលោក ជី យីកគង់ ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង១២០សេះ	១៣០១

១២.៦.១៩៩៧ ប្រកាសលេខ ៥៨១ ផក.ប្រក អនុញ្ញាតឱ្យលោក កែវ រិទ្ធដេត ជនជាតិ
ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង១២០សេះ ១៣០២

១២.៦.១៩៩៧ ប្រកាសលេខ ៥៨២ ផក.ប្រក អនុញ្ញាតឱ្យលោក យា យ៉ុង ជនជាតិ
ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង២៤សេះ ១៣០២

១២.៦.១៩៩៧ ប្រកាសលេខ ៥៨៣ ផក.ប្រក អនុញ្ញាតឱ្យលោក លាង ហុង ជនជាតិ
ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតទឹកត្រី ១៣០៣

១២.៦.១៩៩៧ ប្រកាសលេខ ៥៨៤ ផក.ប្រក អនុញ្ញាតឱ្យលោក ទា ហ៊ុយ ជនជាតិ
ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងគ្រឿងដែក ១៣០៣

១២.៦.១៩៩៧ ប្រកាសលេខ ៥៨៥ ផក.ប្រក អនុញ្ញាតឱ្យលោក ឡូ រ៉ា ជនជាតិ
ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងជួសជុលគ្រឿងបន្លាស់
គ្រឿងដែក និងគោន ១៣០៤

១២.៦.១៩៩៧ ប្រកាសលេខ ៥៨៦ ផក.ប្រក អនុញ្ញាតឱ្យលោក ម៉ក់ សេង ជនជាតិ
ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងគ្រឿងដែក ១៣០៤

១២.៦.១៩៩៧ ប្រកាសលេខ ៥៨៧ ផក.ប្រក អនុញ្ញាតឱ្យលោក ប្រាក់ កូវ ជនជាតិ
ខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងជាងគ្រឿងដែក ១៣០៥

២. នីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១០.៦.១៩៩៧ ប្រកាសលេខ ១៣៤ / ៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៣០៥

១០.៦.១៩៩៧ ប្រកាសលេខ ១៣៦ / ៩៧ ពម.ប្រក ទទួលស្គាល់ លោកHOANG
VAN HUNGជាប្រធាន និងលោក NGUYEN VAN
DUC ជាសមាជិកបុគ្គលិកការិយាល័យទូរទស្សន៍វៀតណាម(VTC.POC)
ប្រចាំព្រះរាជាណាចក្រកម្ពុជា ១៣០៧

១០.៦.១៩៩៧ ប្រកាសលេខ ១៣៧/ ៩៧ ពម.ប្រក អនុញ្ញាតឱ្យចេញផ្សាយឡើងវិញ
និងប្តូរឈ្មោះសារពត៌មាន " ជីវិតកំសាន្ត " មកជាសៀវភៅ "រាយនាម
អាជីវកម្មកម្ពុជា " ១៣០៨

១១.៦.១៩៩៧ ប្រកាសលេខ ១៣៨/ ៩៧ ពម.ប្រក អនុញ្ញាតឱ្យ លោក ថៃ វ៉ាន់
ប្រធានក្រុមហ៊ុនទូរទស្សន៍ ខ្សែកាប្លក្រុងព្រះសីហនុ តំលើងអង់តែនផ្សាយ

បន្តពីបញ្ចេញចូលទេសចរណ៍ទៅរាជធានីភ្នំពេញ នៅលើកំពូលភ្នំបូកគោ ១៣១០
១២.៦.១៩៩៧ ប្រកាសលេខ ១៣៩ / ៩៧ ពម.ប្រក អនុញ្ញាតឱ្យ លោក DULAC នាំចូលនិងចែកផ្សាយសៀវភៅ មានចំណងជើង PHNOM PENH DEVELOPPEMENT URBAIN ET PATRIMOINE នៅមូវាំងព្រះរាជាណាចក្រកម្ពុជា ១៣១១
១២.៦.១៩៩៧ ប្រកាសលេខ ១៤១ / ៩៧ ពម.ប្រក អនុញ្ញាតឱ្យលោក ម៉េង ហាវ សញ្ជាតិកម្ពុជា បើកអាជីវកម្មរោងពុម្ព ឈ្មោះ " ម៉េង ហាវ " ១៣១៣
១២.៦.១៩៩៧ ប្រកាសលេខ ១៤២ / ៩៧ ពម.ប្រក អនុញ្ញាតឱ្យចេញផ្សាយបន្ថែម ព្រឹត្តិប័ត្រ PHNOM PENH DAILY ជាភាសាអង់គ្លេស និងបារាំង ១៣១៤

៣. នីតិស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

ប្រកាស

០៩.៦.១៩៩៧ ប្រកាសលេខ ៤៨ សក.សជ ស្តីពីការកែសម្រួលផែនការគ្រប់គ្រងសុខាភិបាល ខេត្តរតនគិរី ១៣១៥

៤. នីតិស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

០៩.៦.១៩៩៧ ប្រកាសលេខ ៤២២ អយក.ប្រក ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពសៀវភៅកែលម្អវិទ្យា "សំរាប់គ្រូថ្នាក់ទី២" ១៣១៧

៥. នីតិស្តីការ ក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

១១.៦.១៩៩៧ សេចក្តីសំរេចលេខ ១១៤ /៩៧ កធស អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះត្រៃសុត្តនិកាយប្រូតេស្តង់-ក្រុមសាវ័កថ្មី ឈ្មោះថា " សាវ័កថ្មីភូមិដំណាក់ទ្រព្យ " ឃុំត្រាំស្លាយ ស្រុកឈូក ខេត្តកំពត ១៣១៨
១១.៦.១៩៩៧ សេចក្តីសំរេចលេខ ១១៥ /៩៧ កធស អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះត្រៃសុត្តនិកាយប្រូតេស្តង់-ក្រុមសាវ័កថ្មី ឈ្មោះថា " សាវ័កថ្មីអូរស្តៅ " ឃុំស្វាយអាត់ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ១៣២០

I - រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ២២ អនក្រ.បក

ស្តីពីការ ប្រើប្រាស់គណនីឯកជនភាគទុបនីយកម្មសហគ្រាស សាធារណៈ សំរាប់និញ្ញដែកបេតុង និង គ្រឿងចក្រសាងសង់ផ្លូវ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤.
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០១សប្រក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃ ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១ : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ លើមុខសញ្ញាដូចខាងក្រោម ÷

-ក្រសួងសាធារណការនិងដឹកជញ្ជូន :

+ បំពាក់គ្រឿងចក្រសាងសង់ផ្លូវ ចំនួន 1.000.000USD (មួយលានដុល្លារអាមេរិក)

+ ទិញដែកបេឡេ និង រថយន្ត ១០គ្រ. ចំនួន 1.000.000USD (មួយលានដុល្លារអាមេរិក)

-ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ :

+ ទិញដែកបេឡេ សំរាប់ស្ពានធារាសាស្ត្រ ២០០ម ចំនួន 150.000 USD (មួយរយហាសិបពាន់ ដុល្លារអាមេរិក)

ចំនួនទឹកប្រាក់ពិតប្រាកដ នឹងកំណត់ក្រោយពីធ្វើបែបបទលទ្ធកម្មសាធារណៈរួច ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ២៣ អនក្រ.បក

ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាស

សាធារណៈសំរាប់ជួសជុលស្នាក់ការគណៈកម្មាធិការអន្តរជាតិឧន្លេមគន្ធ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះ រាជក្រម លេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០១សប្រក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃ ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ លើមុខសញ្ញាជួសជុលស្នាក់ការគណៈកម្មាធិការអន្តរជាតិទន្លេមេគង្គនៅរាជធានីភ្នំពេញ ដែលមានទឹកប្រាក់ប្រមាណ 600.000 USD (ប្រាំមួយរយពាន់ ដុល្លារអាមេរិក) ។ ចំនួនទឹកប្រាក់ពិតប្រាកដ នឹងកំណត់ក្រោយពីធ្វើបែបបទលទ្ធកម្មសាធារណៈរួច ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ — នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខានិងត្រា — ហត្ថលេខានិងត្រា

ណរោត្តម រណឫទ្ធិ — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ២៤ អនក្រ.បក

ស្តីពីការបង្កើតគណៈកម្មការជាតិអេស្កាប់

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយកយករដ្ឋមន្ត្រីទី ១ និងទី ២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការជាតិសេដ្ឋកិច្ចនិងសង្គមកិច្ច សំរាប់តំបន់អាស៊ីប៉ាស៊ីហ្វិក (Economic and Social Commission for Asia and Pacific) ដែលហៅកាត់ថា « គណៈកម្មការជាតិ អេស្កាប់ (E S C A P) ហើយមានសមាសភាពដូចតទៅ ÷

១-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន	ជាប្រធាន
២-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងផែនការ	ជាអនុប្រធាន
៣-ឯកឧត្តម អគ្គលេខាធិការ គជស/កអក.	ជាសមាជិក
៤-តំណាង អេស្កាប់ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងបាងកក ប្រទេសថៃឡង់ដ៍	ជាសមាជិក
៥-តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ជាសមាជិក
៦-តំណាងក្រសួងពាណិជ្ជកម្ម	ជាសមាជិក
៧-តំណាងក្រសួងទេសចរណ៍	ជាសមាជិក
៨-តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល	ជាសមាជិក
៩-តំណាងក្រសួងបរិស្ថាន	ជាសមាជិក
១០-តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	ជាសមាជិក
១១-តំណាងក្រសួងអប់រំ យុវជននិងកីឡា	ជាសមាជិក

១២–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
១៣–តំណាងក្រសួងកិច្ចការនារី	ជាសមាជិក
១៤–តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	ជាសមាជិក
១៥–តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ	ជាសមាជិក
១៦–អនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គ	ជាសមាជិក
១៧–តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	ជាសមាជិក
១៨–តំណាងក្រសួងសុខាភិបាល	ជាសមាជិក

មាត្រា២ : គណៈកម្មការជាតិ អេស្កាប់ មានភារកិច្ចនិងតួនាទី :

–ជាគណៈបញ្ជាការឯកភាពមួយដោយសហការយ៉ាងជិតស្និទ្ធ និងសំរបសំរួលជាមួយបណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធ ដើម្បីប្រមូលផ្តុំបណ្តាសំណូមពរចាំបាច់បំរើអោយការស្តារឡើងវិញ ការកសាងនិងអភិវឌ្ឍន៍សេដ្ឋកិច្ច–សង្គមកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

–តាមដានការរីកចំរើននៃសកម្មភាពរបស់អង្គការនេះ ។

–រាយការណ៍ និងសុំយោបល់ពីរាជរដ្ឋាភិបាលអំពីបញ្ហាសំខាន់ៗដែលហួសពីសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ៣ : គណៈកម្មការជាតិ អេស្កាប់ចាំបាច់ត្រូវរៀបចំថវិកាដោយឡែកមួយ តែជាឧបសម្ព័ន្ធថវិការបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីកិច្ចដំណើរការអោយមានប្រសិទ្ធភាពរបស់គណៈកម្មការជាតិអេស្កាប់ ។

មាត្រា ៤ : គណៈកម្មការជាតិ អេស្កាប់ ត្រូវមានត្រាដោយឡែករបស់ខ្លួន ។

មាត្រា ៥ : សមាជិកគណៈកម្មការជាតិ អេស្កាប់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធានក្នុងករណីអវត្តមានរបស់ប្រធាន ។

មាត្រា ៦ : គណៈកម្មការជាតិ អេស្កាប់ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនសំរាប់ដំណើរការជាក់ស្តែង ។

មាត្រា ៧ : គណៈកម្មការជាតិ អេស្កាប់ មានការិយាល័យប្រតិបត្តិមួយនៅទីស្តីការក្រសួងសាធារណការនិងដឹកជញ្ជូន ។

មាត្រា ៨ : ការិយាល័យប្រតិបត្តិនេះ មានសមាសភាពដូចខាងក្រោម ៖

១– តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន ជាប្រធាន

២– តំណាងក្រសួងផែនការ ជាអនុប្រធាន

៣– តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៤– តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

ការិយាល័យប្រតិបត្តិនេះមានបុគ្គលិកបំរើការអចិន្ត្រៃយ៍មួយចំនួន តាមការរៀបចំរបស់គណៈកម្មការជាតិ អេស្កាប់ ។

មាត្រា ៩ : ការិយាល័យប្រតិបត្តិនេះ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម ៖

– ជាយន្តការជំនួយការអចិន្ត្រៃយ៍របស់គណៈកម្មការជាតិ អេស្កាប់ ។

– រៀបចំកម្មវិធី និងខ្លឹមសារសំរាប់អង្គប្រជុំនៃគណៈកម្មការជាតិ អេស្កាប់ ។

– ជំរុញនិងតាមដានការអនុវត្តន៍សេចក្តីសំរេចរបស់អង្គការ អេស្កាប់ ។

– សិក្សាស្រាវជ្រាវនិងលើកឡើងជំនួរវិធានការនានា សំរាប់អង្គប្រជុំនៃអង្គការអេស្កាប់ជូនគណៈកម្មការជាតិ អេស្កាប់ ។

– ប្រមូលផ្តុំចម្លង និងចែកចាយឯកសារ ដល់គ្រប់ក្រសួង ស្ថាប័នលើការងារពាក់ព័ន្ធ ។

– ធ្វើរបាយការណ៍តាមកាលកំណត់ជូនគណៈកម្មការជាតិ អេស្កាប់ ។

មាត្រា ១០ : អនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៥ ត្រូវបានទុកជានិរាករណ៍ ។

មាត្រា ១១ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងផែនការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានគណៈកម្មាធិការជាតិទន្លេ

មេគង្គ ឯកអគ្គរាជទូតកម្ពុជាប្រចាំរាជាណាចក្រថៃម្យ៉ាងទៀត និងសាមីខ្លួនដូចមាន ចែងក្នុងមាត្រា ១ និងមាត្រា ៨ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ២៥ អនក្រ.បក

ស្តីពីការបង្កើតគណៈកម្មាធិការ

សំរាប់គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា

- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ទេសាភិបាលនៃ ធនាគារជាតិនៃកម្ពុជា
- យោងតាមតម្រូវការចាំបាច់នៃការងារ

សំរេច

មាត្រា ១ : បង្កើតគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរាប់រៀបចំ និងតាមដានការអនុវត្តន៍អនុស្សារណៈ ស្តីពីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និង សំរាប់ជាផែនត្អកុងកិច្ចប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ពិសេសជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ នៅក្នុងក្របខ័ណ្ឌ «កម្មវិធី ផ្តត់ផ្គង់កំណែតម្រូវរចនាសម្ព័ន្ធ »។

មាត្រា២ : គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសមាសភាពដូចតទៅ ÷

១–ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន
២–ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា អនុប្រធាន
៣–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៤–តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សមាជិក
៥–តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
៦–តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល សមាជិក
៧–តំណាងក្រសួងផែនការ សមាជិក
៨–តំណាងក្រសួងទេសចរណ៍ សមាជិក
៩–តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

ក្នុងករណីអវត្តមានរបស់ប្រធាននិងអនុប្រធាន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា ត្រូវទទួលបន្ទុកជាប្រធាន និងអនុប្រធានដោយស្វ័យប្រវត្តិ ។

មាត្រា ៣ : គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់អង្គភាពសេដ្ឋកិច្ចនៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន ។

មាត្រា ៤ : គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងរបស់ប្រធានស្ថាប័ន ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង និងស្ថាប័នពាក់ព័ន្ធមកចូលរួមប្រជុំ ដើម្បីដោះស្រាយការងារនៃការរៀបចំ និងការតាមដានការអនុវត្តន៍អនុស្សាវរណៈស្តីពីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

មាត្រា ៥ : គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការតាមការអញ្ជើញរបស់ប្រធាន។

មាត្រា ៦ : គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិអញ្ជើញតំណាងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ប្រចាំនៅប្រទេសកម្ពុជា អោយចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

មាត្រា ៧ : ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលនៃធនាគារជាតិកម្ពុជា សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងគ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

ភ្នំពេញ,ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ២៦ អនក្រ.បក

ស្តីពីការអនុវត្តន៍ទំរង់ឧបត្ថម្ភប្រចាំខែ/ឆ្នាំ (?)

ជាមួយខេត្តកំពត ត្រង់ចំណុចបំការបី

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការប្តូរឋានៈសម្ព័ន្ធ រដ្ឋបាលក្រុងកែប ពីថ្នាក់ស្រុក មកជាថ្នាក់ក្រុង
- តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានកែសំរួលព្រំប្រទល់រដ្ឋបាល រវាងក្រុងកែប និងខេត្តកំពតដោយកាត់យកផ្ទៃដីចំនួន ២០.៣០ គីឡូម៉ែត្រក្រឡា ត្រ[illegible] ប.«ចំការបី» ពីស្រុកកំពត ក្រោយខេត្តកំពត ប្រគល់អោយក្រុងកែបគ្រប់គ្រងតាមផែនទីមាត្រដ្ឋាន ១/៥០.០០០ ដែលមានកូអ័រដោណេដូចខាងក្រោម :

	X	Y
A-	៦៩.០០	៣០.៥០
B-	៧០.០០	៣០.៧៥
C-	៧០.៤៥	៣១.២០
D-	៧០.៣៥	៣១.៥០
E-	៧១.០០	៣២.២០
F-	៧១.០០	៣៦.០០
G-	៦៥.២០	៣៦.០០
H-	៦៤.៧០	៣៤.២០

មាត្រា ២ : ...រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលខេត្តកំពត និងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកក្រុងកែបត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣ : អនុក្រឹត្យនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

ភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ៥៣ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើឯកឧត្តម ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ និងជាអនុប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរអប្សរា

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងទីប្រឹក្សា ២រូប សំរាប់ក្រុមប្រឹក្សាភិបាលអាជ្ញាធរអប្សរានិងសំរាប់គណៈកម្មាធិការ ជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ សមាសភាពមាន :

១-លោកស្រី អេងស៊ុន ភិរិយា ជានាយក នៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍នៃអាជ្ញាធរអប្សរា

២-លោកស្រី **ឆេត ទត្ត** ជានាយក នៃនាយកដ្ឋាននគរូបនីយកម្ម នៃ អាជ្ញាធរអប្សរា

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មន្ត្រីក្រសួងវប្បធម៌និង វិចិត្រសិល្បៈ ឯកឧត្តមទេសរដ្ឋមន្ត្រី **វណ្ណ មូលីវណ្ណ** និងលោកស្រីដែលមាននាមក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ៥៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគថវិកាជួយកសាងអគារសិក្សា ០៤ខ្នង មាន ១៦បន្ទប់ និងទីចាត់ការ ០១ខ្នង នៅសាលាបឋមសិក្សាបុសថ្កាំង ឃុំបុសមន ស្រុករំដួល ខេត្តស្វាយរៀងដូចមាននាមខាងក្រោមនេះ ៖

១-លោកឧកញ៉ា **សៅ សេរីមុន្នី** ហៅ **យ៉ាត** ទឹកប្រាក់ ៧៩.២៥០ ដុល្លារអាមេរិក

២-លោក **សៅ មុន្នីរស្មី** ទឹកប្រាក់ ១៥.០០០ ដុល្លារអាមេរិក

មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ៥៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

*****

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

–តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

សំរេច

ប្រការ ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនលោកឧញ៉ា **សោ សេរីមុន្នី** ហៅ **សោ យ៉ាត** ដែលបានជួយកសាងសាលារៀននៅស្រុករមាសហែក ជួយឧបត្ថម្ភម៉ាស៊ីនដេរ និងគ្រូភាសាអង់គ្លេសនៅវិទ្យាល័យស្វាយរៀង និងជួយឧបត្ថម្ភគោ ក្របី អណ្តូងទឹក ព្រមទាំងរបងសាលាស្រុក ជូនប្រជាជនស្រុករំដួល ខេត្តស្វាយរៀង អស់ទឹកប្រាក់សរុបចំនួន ១០.១៤០ ដុល្លារសហរដ្ឋអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ | **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ៥៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ មាស ស្ថាបនាជាតិ ជូនលោកឧកញ៉ា **សៅ សេរីមុន្នី** ដែលបានជួយឧបត្ថម្ភដល់មន្ទីរពេទ្យក្រាំងយ៉ូវ នូវប្រព័ន្ធបរិក្ខារអគ្គិសនីដើរដោយថាមពលព្រះអាទិត្យមានតំលៃគិតជាទឹកប្រាក់ចំនួន ១៥.០០០ដុល្លារសហរដ្ឋអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

សារាចរ

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៧

សារាចរលេខ ០៣ សរ

ស្តីពីបែបបទ និងនីតិវិធីនៃការស្នើសុំរួចពន្ធឧបករណ៍សំភារៈនាំចូល

ក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និង ជំនួយមនុស្សធម៌

* * * *

កន្លងមក រាជរដ្ឋាភិបាលបានពិនិត្យឃើញ មានការយឺតយ៉ាវខ្លះក្នុងការស្នើសុំ និងដោះស្រាយអោយរួចពន្ធនូវការនាំចូលឧបករណ៍ សំភារៈក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និងជំនួយមនុស្សធម៌ ដែលជាមូលហេតុមួយធ្វើអោយការអនុវត្តន៍គំរោងការមួយចំនួន ប្រព្រឹត្តទៅមិនបានតាមកម្មវិធីដែលបានគ្រោងទុក ។

ដើម្បីជំរុញល្បឿនក្នុងការស្នើសុំ និងដោះស្រាយអោយរួចពន្ធនូវការនាំចូលឧបករណ៍សំភារៈ ក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និងជំនួយមនុស្សធម៌ រាជរដ្ឋាភិបាលបានកំណត់បែបបទ និងនីតិវិធីដូចខាងក្រោម ÷

១–ស្ថាប័នអនុវត្តគំរោងចាំបាច់ត្រូវរៀបចំតារាងបញ្ជី (Master List) ឧបករណ៍ សំភារៈ នាំចូលសំរាប់ប្រើប្រាស់ក្នុងគំរោងការនីមួយៗ រួចផ្ញើជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ (ករអក/គជនា) ។

២–ចំពោះសំណើនាំចូលឧបករណ៍ សំភារៈរួចពន្ធសំរាប់អនុវត្តគំរោងការក្នុងក្របខ័ណ្ឌជំនួយឥតសំណង (ទ្វេភាគី ពហុភាគី និងអង្គការក្រៅរដ្ឋាភិបាល) សាមីស្ថាប័នជាអ្នកអនុវត្តគំរោងការឬស្ថាប័នទទួលជំនួយ ត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេចតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ ។

៣–ចំពោះសំណើនាំចូលឧបករណ៍ សំភារៈរួចពន្ធ ក្នុងក្របខ័ណ្ឌឥណទាន និងជំនួយបច្ចេកទេសផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀង (ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក...) សាមីស្ថាប័នអនុវត្តន៍គំរោងការត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសំរេច ។

៤–ចំពោះសំណើនាំចូលឧបករណ៍ សំភារៈរួចពន្ធ ក្នុងក្របខ័ណ្ឌជំនួយមនុស្សធម៌ សាមីស្ថាប័នទទួលជំនួយនោះ ត្រូវបំពេញទំរង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បី ពិនិត្យនិងសំរេច ។

៥–ឯកសារយោងសំខាន់ៗសំរាប់បំពេញបែបបទស្នើសុំមានដូចខាងក្រោម :

–កិច្ចព្រមព្រៀង ឬ ឯកសារដែលមានតំលៃប្រហាក់ប្រហែល

–បញ្ជីរាយនាមមុខទំនិញ Packing List

–វិក្កយបត្រ Invoice

–អញ្ញាតប័ណ្ណ Bill of Loading

រាជរដ្ឋាភិបាលសូមស្ថាប័នទាំងអស់ យកចិត្តទុកដាក់ក្នុងការអនុវត្តន៍សារាចរនេះ អោយមាន ប្រសិទ្ធភាព ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

II - ការងារបណ្តាក្រសួង

១_ទីស្តីការដ្ឋានរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៥៤៣ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ហាំ ឆេង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣១៨៧៦ ភ.ព ចុះថ្ងៃទី ១០.៥.៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៥១ E0 ផ្លូវហ្សាលជីហ្គោល សង្កាត់អូរឫស្សីទី២ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បន្តដំណើរការរោងជាងផលិតចោត ធុង នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៤៤ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សែម ចាន់ណា** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩០៨៤៥ ភ.ព ចុះថ្ងៃទី ១៨.៣.៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៥ E0 ផ្លូវលេខ ១៦៣ សង្កាត់វាលវង់ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញបន្តដំណើរការរោងជាងជួសជុលរថយន្ត នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ

សច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៤៥ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ែន សាទុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៥១៣២៣ ភ.ព ចុះថ្ងៃទី ០៣.៨.៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥១ E0 ផ្លូវលេខ ៣៣៦ សង្កាត់វាលវង់ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បន្តដំណើរការរោងជាងជួសជុលប៉ុមអាំងហ្ស៊ិកស្យុងរថយន្ត នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៤៦ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឌឹម ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១០៤៤៨៩ ភ.ព ចុះថ្ងៃទី ២៦.៤.៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦C ផ្លូវលេខ ២៧៨ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញបន្តដំណើរការសិប្បកម្មផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំងភូមិឡូកំបោរ សង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ

ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៤៧ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **កែវ ម៉ី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣០៦១៣៩ ភ.ព ចុះថ្ងៃទី ១៥.៩.៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦៩ ផ្លូវលេខ ២៧៨ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតជ្ជ-គ្រឿង នៅក្នុងទីតាំងភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៤៩ ឧក.ប្រក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ច័ន្ទ កុសល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២២៥០០ ភ.ព ចុះថ្ងៃទី ១៥.៣.៩០ អាស័យដ្ឋានបច្ចុប្បន្ន មណ្ឌល២ សង្កាត់លេខ ២ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ បន្តដំណើរការសិប្បកម្មផលិតស្រាកែច្នៃ យីហោ «លី ហ៊ុយតឹង» នៅក្នុងទីតាំងក្រុមទី៤៤ មណ្ឌល១ សង្កាត់លេខ៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

ប្រការ ២ : លោក **ច័ន្ទ កុសល** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលស្រាកែច្នៃ យីហោ «លី ហ៊ុយតឹង» ចំនួន ២ មុខ គឺស្រាសាំងហ៊ុ សញ្ញា «រូបដើមយិនស៊ិន»

និ.. ..ាសញ្ញា «រូបមនុស្សស្រី» ស្របតាមតំរូវសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ៥៥០ ឧក.ប្រក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឌុន គុយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៩៥០៦៤ ប.ប ចុះថ្ងៃទី ១១.១០.៩៣ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្តុល ឃុំក្តុល ស្រុកស្វាយចេក ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២០សេះ នៅក្នុងទីតាំងភូមិស្ទឹងលិច ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឌុន គុយ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦. ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ៥៥១ ឧក.ប្រក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **គួ សុឃឿម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៤២៣៦១ ប.ប ចុះថ្ងៃទី ១១.០១.៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្រពើជើង ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ៨០សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **គួ សុឃឿម** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

ប្រកាសលេខ ៥៥២ ឧក.ប្រក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ទីយ សារ៉េន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០០២៧៤ ប.ប ចុះថ្ងៃទី ១៦.៥.៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំងភូមិសែសិន ឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៥៣ ឧក.ប្រក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **គួណ ម៉ិនរិទ្ធ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៦២៨៧៨ ប.ប ចុះថ្ងៃទី ៦.១១.៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកាប់គោថ្មី ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការសិប្បកម្មដេរពូកឡាន-ម៉ូតូ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ៥៥៥ ឋឈ.ប្រក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : បង្កើតការិយាល័យអភិវឌ្ឍន៍តំបន់ឧស្សាហកម្ម ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានបច្ចេកទេសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ២ : ការិយាល័យនេះមានភារកិច្ច និងសិទ្ធិអំណាចដូចតទៅ :

១_សិក្សាស្រាវជ្រាវវាយតំលៃតំរូវការ និងលទ្ធភាពសំរាប់ការអភិវឌ្ឍន៍ តំបន់ឧស្សាហកម្ម ។

២_ជំរុញការវិនិយោគទុន ផ្នែកតំបន់ឧស្សាហកម្មទូទៅ និងតំបន់ឧស្សាហកម្មសំរាប់នាំចេញនៅក្នុងប្រទេស ។

_ពិនិត្យវាយតំលៃគំរោងស្នើសុំបង្កើតឧស្សាហកម្មទូទៅនិងឧស្សាហកម្មសំរាប់នាំចេញ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសំរេច ។

៣_សិក្សាជ្រើសរើស និងកំណត់ទីតាំងសមស្រប សំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មទូទៅ និងឧស្សាហកម្មសំរាប់នាំចេញ ។

៤_គ្រប់គ្រង និងត្រួតពិនិត្យការបង្កើត និងការសាងសង់ឧស្សាហកម្មទូទៅ និងឧស្សាហកម្មសំរាប់នាំចេញ ។

៥_ណែនាំវិនិយោគគិនក្នុងវិស័យឧស្សាហកម្មទូទៅ និងឧស្សាហកម្មសំរាប់នាំចេញ អោយអនុវត្ត និងគោរពតាមលក្ខខណ្ឌដែលបានចែងក្នុងលិខិតបទដ្ឋាន បទបញ្ញត្តិនានា និងអាជ្ញាប័ណ្ណប្រតិបត្តិរបស់ក្រសួង ។

៦_ការងាររដ្ឋបាល

ប្រការ ៣ : ការិយាល័យអភិវឌ្ឍន៍តំបន់ឧស្សាហកម្ម ត្រូវគ្រប់គ្រងដោយប្រធានមួយរូប អនុប្រធានមួយចំនួន និងមានក្រុមការងារមួយចំនួនតាមការចាំបាច់ ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ គ្រប់ប្រធាននាយកដ្ឋាន ប្រធានគណៈកម្មាធិការត្រួតពិនិត្យ ត្រូវអនុវត្តនូវប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីពេលចុះហត្ថលេខានេះទៅ ។

ប្រកាសលេខ ៥៥៦ បឈ. ប្រក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : បង្កើតការិយាល័យកម្មសិទ្ធិតំបន់ឧស្សាហកម្ម ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានបច្ចេកទេសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ២ : ការិយាល័យកម្មសិទ្ធិឧស្សាហកម្មមានភារកិច្ចដូចតទៅ :

១_ទទួលចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្មរួមមាន សញ្ញាសំគាល់ផលិតផល និងសញ្ញាសំគាល់សេវា(ក្នុងស្រុក) ប្រកាសនិយប័ត្រតក្កកម្មនៃការស្រាវជ្រាវរកឃើញ នៃគំនូរ និងរាងគំរូឧស្សាហកម្ម ។

២_តំកល់ទុកឯកសារនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្មដែលបានផ្តល់អោយម្ចាស់កម្មសិទ្ធិ ។

៣_រៀបចំកសាងគោលការណ៍ ស្តីពីកម្មសិទ្ធិឧស្សាហកម្ម ។

៤_ចងក្រង និងបោះពុម្ពផ្សាយសៀវភៅពតិមានជាផ្លូវការ ស្តីពីការចុះបញ្ជីសញ្ញាសំគាល់ និងស្តីពីការចេញប្រកាសនិយប័ត្រតក្កកម្ម ។

៥_ប្រមូល និងផ្សព្វផ្សាយពត៌មានក្នុងប្រទេស និងអន្តរជាតិ ស្តីពីកម្មសិទ្ធិឧស្សាហកម្ម ។

ប្រការ ៣ : ការិយាល័យកម្មសិទ្ធិតំបន់ឧស្សាហកម្ម ត្រូវគ្រប់គ្រងដោយប្រធានមួយរូប អនុប្រធានមួយចំនួន និងមានក្រុមការងារមួយចំនួនតាមការចាំបាច់ ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ គ្រប់ប្រធាននាយកដ្ឋាន ប្រធានគណៈកម្មាធិការត្រួតពិនិត្យ ត្រូវអនុវត្តនូវប្រកាសនេះតាមមុខងាររៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីពេលចុះហត្ថលេខានេះទៅ ។

* * *

ប្រកាសលេខ ៥៥៧ បឈ.ប្រក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : បង្កើតការិយាល័យអភិវឌ្ឍន៍តំបន់ឧស្សាហកម្ម ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានបច្ចេកទេសនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ២ : ការិយាល័យស្តង់ដាឧស្សាហកម្មភារកិច្ច និងសិទ្ធិអំណាចដូចតទៅ :

១_រៀបចំចងក្រងគោលការណ៍ ស្តីពីការងារស្តង់ដានៅកម្ពុជា

២_ធ្វើការផ្សាយអំពីការងារស្តង់ដាក្នុងវិស័យឧស្សាហកម្ម

៣_ទំនាក់ទំនងប្រមូលឯកសារស្តង់ដា អំពីបណ្តាប្រទេសជាសមាជិករបស់អង្គការស្តង់ដា អន្តរជាតិ ISO និងសំរបសំរួលកិច្ចទំនាក់ទំនងខាងផ្នែកស្តង់ដាអន្តរជាតិ

៤_រៀបចំចងក្រង និងណែនាំអនុវត្តស្តង់ដាជាតិ អំពីផលិតផលឧស្សាហកម្ម អំពីប្រព័ន្ធគ្រប់គ្រងគុណភាព និងអំពីប្រព័ន្ធគ្រប់គ្រងបរិស្ថាន

៥_រៀបចំទំរង់បែបបទសំរាប់ការចេញវិញ្ញាបនប័ត្របញ្ជាក់ អំពីផលិតផលឧស្សាហកម្ម

៦_រៀបចំទំរង់បែបបទសំរាប់ការចេញវិញ្ញាបនប័ត្របញ្ជាក់ អំពីការគ្រប់គ្រងប្រព័ន្ធគុណភាពក្នុងផលិតកម្ម

៧_រៀបចំទំរង់បែបបទសំរាប់ការចេញវិញ្ញាបនប័ត្របញ្ជាក់ អំពីការគ្រប់គ្រងប្រព័ន្ធបរិស្ថានឧស្សាហកម្ម

៨_រៀបចំទំរង់បែបបទ ដើម្បីទទួលស្គាល់អំពីសមត្ថភាពរបស់មន្ទីរពិសោធន៍ទាំងឡាយក្នុងការធ្វើតេស្តលើទិដ្ឋភាពជាក់លាក់ ឬលើប្រភេទជាក់លាក់

៩_ផ្សព្វផ្សាយឯកសារពត៌មានអំពីការងារស្តង់ដា ក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ

ប្រការ ៣ : ការិយាល័យស្តង់ដាតំបន់ឧស្សាហកម្ម ត្រូវគ្រប់គ្រងដោយប្រធានមួយរូប អនុប្រធានមួយចំនួន និងមានក្រុមការងារជំនាញមួយចំនួនតាមតំរូវការចាំបាច់ ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ គ្រប់ប្រធាននាយកដ្ឋាន ប្រធានគណៈកម្មាធិការត្រួតពិនិត្យត្រូវមានភារកិច្ចអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខានិងត្រា

ពូ សុធីរៈ

* * *

ប្រកាសលេខ ៥៦៨ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ សន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៦៩២៤ ភ.ព ចុះថ្ងៃទី ១៤.៤.៨៩ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៧៣ AE0 មហាវិថីព្រះមុនីវង្ស ក្រុមទី២ សង្កាត់បឹងព្រលិត ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មផលិតស្រាកែច្នៃ នៅក្នុងទីតាំងភូមិស្វែង សង្កាត់ផ្សារអំពៅទី២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **សុខ សន** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ស្រាកែច្នៃ ចំនួន ៣មុខគឺ : ស្រាសញ្ញា BLACK TABLE , «ស្រាសញ្ញា» Benassy និងស្រាសញ្ញា «មុខយក្ស» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ

ល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយ មា ពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ៥៦៩ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឡា អន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៦៤១២៤ ភ.ព ចុះថ្ងៃទី ២១.៦.៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥ E0 ផ្លូវលេខ ២១៥ សង្កាត់ផ្សារដេប៉ូ ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្មកែច្នៃឈើ នៅក្នុងទីតាំងភូមិវល្លិយោង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ។

ប្រការ ២ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សិប្បកម្មត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៣ : សិប្បកម្មនេះ ត្រូវបានអនុញ្ញាតអោយផលិតឬមុខផលិតផលជាសារវន្ត: ដើមឈើកែច្នៃ ។ វត្ថុធាតុដើម ដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើចាស់ដែលមានលក្ខណ:ស្របច្បាប់ ដែលសាមីសិប្បកម្មត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៤ : ម្ចាស់សិប្បកម្មត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់សិប្បកម្មផ្ញើជូនមកក្រសួងតាមរយ:មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តមណ្ឌលគិរី ។

ប្រការ ៥ : ប្រកាសនេះមានតំលៃក្នុងរយ:ពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ហត្ថលេខា និង ត្រា

អ៊ិត ប្រាំង

ប្រកាសលេខ ៥៧០ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ុង គឹមឈី** ជាប្រធានសិប្បកម្មផលិតឥដ្ឋ-ក្បឿង ដែលមានទីតាំងភូមិពពលខែ ឃុំជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ផ្ទេរភារកិច្ចគ្រប់គ្រងលើសិប្បកម្មនេះ ជូនលោក **លី មាន** វិញ ។

ប្រការ ២ : ទទួលស្គាល់លោក លី មាន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣២៤៦០ ប.ប ចុះថ្ងៃទី ១១.៩.៨៩ អាសយដ្ឋានបច្ចុប្បន្ន ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ជាម្ចាស់សិប្បកម្មផលិតឥដ្ឋ-ក្បឿង ដែលមានទីតាំងដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៧១ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ហ៊ុន ស៊ីថា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៣៧៦៤១ ប.ប ចុះថ្ងៃទី ១៤.១២.៨៨ ជាប្រធានអាសយដ្ឋានបច្ចុប្បន្ន ភូមិក្បាល ខ្មោច ឃុំជ្រៃ ស្រុកបាត់ដំបងខេត្តបាត់ដំបង បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ១២០ សេះ នៅក្នុងទីតាំងភូមិហែសាន ឃុំជ្រៃ ស្រុកបាត់ដំបង ខេត្ត បាត់ដំបង ។

ប្រការ ២ : លោក **ហ៊ុន ស៊ីថា** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៧២ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឈី សារ៉ាត់** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៨៦៧៥៣ ប.ប ចុះថ្ងៃទី ១១.០១.៩៣ អាស័យដ្ឋានបច្ចុប្បន្នភូមិជ្រោយស្ដៅ ឃុំជ្រោយស្ដៅ ស្រុកបាត់ដំបង ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៧៧សេះ នៅក្នុងទីតាំង ភូមិកៀនកេស១ ឃុំតាកឃុំ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឈី សារ៉ាត់** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ១ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៧៣ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សេង រឿន** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧២៣២៨ ប.ប ចុះថ្ងៃទី ២៣.៣.៩៣ អាស័យដ្ឋានបច្ចុប្បន្នភូមិកាឡោមភ្លុក ឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង បន្តដំណើរការរោង

ម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ នៅក្នុងទីតាំង ភូមិកាឡោមក្លុក ឃុំព្រៃស្វាយ ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **សេង រ៉េន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៧៤ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឌុច ឌិនិត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០០៥៨០៣ ប.ប ចុះថ្ងៃទី ១២.១០.៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ អូរតាគាំ១ ឃុំទួលតាឯក ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីន កិនស្រូវ កំលាំង ៦០សេះ នៅក្នុងទីតាំង ភូមិកំប៉ូវ ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឌុច ឌិនិត** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៧៥ ផក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **លី ហុកហាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥២០៦១ ប.ប ចុះថ្ងៃទី ០៧.៤.៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែកខ្ពប ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣៥សេះ នៅក្នុងទីតាំង ភូមិព្រែកខ្ពប ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **លី ហុកហាន់** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

***

ប្រកាសលេខ ៥៧៦ ផក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉េង គា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៤៨៧២ ក.ព ចុះថ្ងៃទី ១៥.០២.៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិពោធិតូច ឃុំកំពង់ល្ពង ស្រុកពញាឮ ខេត្តកណ្តាល បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំង ភូមិពោធិតូច ឃុំកំពង់ល្ពង ស្រុកពញាឮ ខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយ

មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

ប្រកាសលេខ ៥៧៧ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **និ ជុំ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤២៥១២ កណ. ចុះថ្ងៃទី ៣១.៩.៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិបែកចាន ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល បន្តដំណើរការសិប្បកម្មផលិតនំប៉័ង នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

ប្រកាសលេខ ៥៧៨ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ខាង ឆន់មី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៩៦៦៦ កណ. ចុះថ្ងៃទី ០៣.៧.៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិចុងព្រែក ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល បន្តដំណើរការសិប្បកម្មផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណង ឡើយ ។

ប្រកាសលេខ ៤៧៩ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ជន់ ឈួរ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៨៩៣៨០ កណ. ចុះថ្ងៃទី ១៨.០១.៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិដើមមៀន ឃុំដើមមៀន ស្រុកតាខ្មៅ ខេត្តកណ្តាលបន្តដំណើរការសិប្បកម្មផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៨០ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ឌី យីកសង់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០០៧៨៨ ប.ប ចុះថ្ងៃទី ០២.១២.៩៣ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្ន ភូមិអូរតាវ ឃុំអូរតាវ ស្រុក ស្វាយចេក ខេត្តបាត់ដំបង បើកដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ១២០ សេះ នៅក្នុងទីតាំង ភូមិកកោះ ឃុំអូរតាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឌី យីកសង់** ត្រូវបើកដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានាទទួលទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

ប្រកាសលេខ ៥៨១ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **កែវ វិទ្ធដេត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧១២៥៩ ប.ប ចុះថ្ងៃទី ០២.៩.៨៧ ជាប្រធាន អាសយដ្ឋានបច្ចុប្បន្ន ភូមិអូរខ្ចាយ ឃុំវត្តតាមឹម ស្រុកសង្កែ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ១២០ សេះ នៅក្នុងទីតាំង ភូមិស្លក្រាម ឃុំវត្តតាមឹម ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **កែវ វិទ្ធដេត** ត្រូវបើកដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិលើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ៥៨២ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **យា យ៉ុខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩៥៦៧៣ ប.ប ចុះថ្ងៃទី ១០.១២.៨៧ អាសយដ្ឋានបច្ចុប្បន្ន ភូមិអន្លង់វិល ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ នៅក្នុងទីតាំង ភូមិអូរមុនី ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **យា យ៉ុខ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៨៣ ផក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ហេង ហុង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១០៩៦៣៨ ភព. ចុះថ្ងៃទី ០៦.៤.៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៥៩ ផ្លូវលេខ ៣៦៩ ភូមិដើមចាន់ សង្កាត់ផ្សារដើមថ្កូវទី២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មតូច ផលិតទឹកត្រី នៅក្នុងទីតាំងផ្ទះសង់ថ្មី ក្រុមទី២ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៨៤ ផក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឌា ហ៊ុយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៧១០២ ភព. ចុះថ្ងៃទី ១៨.៥.៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៩០ E0 ផ្លូវហ្សាលដឺហ្គោល ក្រុមទី ៥៩ សង្កាត់អូរឫស្សីទី២ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែក នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្ករអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

បកាសលេខ ៥៨៥ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក ឡូ ទ៊ា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៤៥៦១៣ ភព. ចុះថ្ងៃទី ១២.៧.៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះសង់ថ្មី ផ្លូវលេខ ១៩៩ ក្រុមទី ២២ សង្កាត់ទួលស្វាយព្រៃទី២ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹង ផ្លុសជុលគ្រឿងបន្លាស់ និង តោន នៅក្នុងទីតាំង ផ្ទះលេខ ១៧១ ផ្លូវមុនីរ៉េត ក្រុមទី ៤៩ សង្កាត់ បឹងសាឡាង ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្ករអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៨៦ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ក់ សេខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៥១៦៩៧ ភព. ចុះថ្ងៃទី ១៨.៧.៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២១០២ B ផ្លូវលេខ ៦៨ ក្រុមទី ៥៥ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការរោងជាងក្រឡឹងដែក នៅក្នុងទីតាំងផ្ទះលេខ ២១០២ B ផ្លូវលេខ ៦៨ ក្រុមទី ៥៥ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៨៧ ឧក.ប្រក ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ច្រាក់ គួច** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១២៩៤៧១ ភព. ចុះថ្ងៃទី ០៣.៦.៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២២២៦ B ផ្លូវលេខ ៩៣ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញបន្តដំណើរការរោងជាងក្រឡឹងដែក នៅក្នុងទីតាំង ផ្ទះលេខ ២២២៦ B ផ្លូវលេខ ៩៣ សង្កាត់ ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

២_ ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

ភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៣៤/៩៧ព.មប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពតិមាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណា[illegible]កម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីកា[illegible]ាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ [illegible] ពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម នស-រកម-០១៩៦-១៤ ចុះថ្ងៃទី ២៤ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពតិមាន
- បានឃើញសំណើ ចុះថ្ងៃទី ២០ មករា ឆ្នាំ ១៩៩៧ របស់នាយកដ្ឋានសំភារៈបរិក្ខារ
- យោងតាមការចាំបាច់
- ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងលោក **ហាស់ សាឌុន** ជាប្រធានការិយាល័យគ្រប់គ្រងឃ្លាំងសំភារៈ នាយកដ្ឋានសំភារៈបរិក្ខារ នៃក្រសួងពតិមាន ។

ប្រការ ២ [illegible]កត្តមអគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ លោក[illegible]ខុទ្ទកាល័យបណ្តា អគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានសំភារៈបរិក្ខារ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធានដ្ឋានផែនការ គណនេយ្យហិរញ្ញវត្ថុនិងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

ភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧

ប្រកាសលេខ : ១៣៦/៩៧ ពម.ប្រក

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១ ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បាឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.សរក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។
- បានឃើញលិខិតតែងតាំងសមាជិកបុគ្គលិកការិយាល័យ អចិន្ត្រៃយ៍ទូរទស្សន៍វៀតណាម ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៧ របស់លោកអគ្គនាយកទូរទស្សន៍វៀតណាមនៅទីក្រុងហាណូយ ។
- បានឃើញលិខិតស្នាមឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៧ ។
- បានឃើញលិខិតស្នើសុំចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់លោក HAPANG VAN HUNG

សំរេច

ប្រការ ១ : ទទួលស្គាល់លោក HAPANG VAN HUNG ជាប្រធាន និង លោក NGUYEN VAN DUC ជាសមាជិក បុគ្គលិកការិយាល័យអចិន្ត្រៃយ៍ទូរទស្សន៍វៀតណាម (VTV POC) ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែលមានទីស្នាក់ការនៅផ្ទះលេខ ១៦ មហាវិថីម៉ៅសេទុង រាជធានីភ្នំពេញ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា គោរពច្បាប់សារពត៌មាន តាមគោលការណ៍ ក្រមសីលធម៌អ្នកកាសែតនិងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន។

ប្រការ ៣ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង ប្រធានការិយាល័យអចិន្ត្រៃយ៍ទូរទស្សន៍វៀតណាម (VTV POC) ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ៣ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

ភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៣៧/៧៩ ពម.ប្រក

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១ ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រ.ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។
- បានឃើញប្រកាសរបស់ក្រសួងពត៌មាន លេខ ៨៦៤ ៩៤ពម ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការអនុញ្ញាតអោយសារពត៌មាន«ជីវិតកំសាន្ត» បោះពុម្ព

ចែកផ្សាយដោយលោក ម៉ែន ណារ៉ុង ជាចាងហ្វាងការផ្សាយ និង ប្រកាសបិទលេខ ១៣៤/៩៥ពម.ប្រក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

– បានឃើញសំណើសុំផ្សាយឡើងវិញ និង សុំប្តូរឈ្មោះសារពត៌មានពី «ជីវិតកំសាន្ត» មកជាសៀវភៅ«រាយនាមអាជីវកម្មកម្ពុជា » (The Camdodia Buying Guide) ជាភាសាអង់គ្លេស និង ភាសាខ្មែរវិញរបស់លោក **ម៉ែន ណារ៉ុង** ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយចេញផ្សាយឡើងនិងប្តូរឈ្មោះសារពត៌មានពី«ជីវិតកំសាន្ត» មកជាសៀវភៅ«រាយនាមអាជីវកម្មកម្ពុជា (The Camdodia Buying Guide) ជាភាសាអង់គ្លេស និង ភាសាខ្មែរ ដែលផ្សព្វផ្សាយពត៌មានពាណិជ្ជកម្ម សេវា កម្ម និងវិជ្ជាជីវៈដល់អតិថិជនក្នុងនិងក្រៅប្រទេសវិញដោយមាន លោក ម៉ែន ណារ៉ុង ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ៩ សេ ផ្លូវ ៥១ សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណ នៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណឹងជាមុន ០៥ ថ្ងៃមកក្រសួងពត៌មានដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកសារពត៌មាន ច្បាប់ស្តីពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ ត្រូវប្រគល់សៀវភៅចំនួន ០៦ ក្បាល រៀងរាល់លេខចេញផ្សាយមកដំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស និងសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងនាយកការផ្សាយសៀវភៅ «រាយនាមអាជីវកម្មកម្ពុជា» (The Camdodia Buying Guide) ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល៣ ឆ្នាំ ហើយសេចក្ដីសំរេចណាដែលផ្ទុយនឹងសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

* * *

ភ្នំពេញ,ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៣៨/៩៧ ពម.ប្រក

រដ្ឋមន្ត្រីក្រសួងពត៌មាន

****

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១-១១-៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ន.ស.រ.ក.ម ចុះថ្ងៃទី ២៤-០១-៩៣ ច្បាប់ស្ដីពីការបង្កើតក្រសួងពតិមាន
- យោងប្រកាសលេខ ០០១/៩៦ ព.ម.ប្រ.ក ចុះថ្ងៃទី ០៣-០១-៩៦ របស់ក្រសួងពតិមាន
- យោងលិខិតសំណើសុំតម្លើងអង់តែនផ្សាយបន្តរបស់លោក ថៃ វ៉ាន់ ចុះថ្ងៃទី ១៩-៣-១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក ថៃ វ៉ាន់ ប្រធានក្រុមហ៊ុន ទូរទស្សន៍ខ្សែកាបក្រុងព្រះសីហនុតម្លើងអង់តែនផ្សាយ បន្តពីបណ្ដាញស្ថានីយ៍ទូរទស្សន៍នៅរាជធានី

ភ្នំពេញនៅលើកំពូលភ្នំបូកគោ និងក្នុងបរិវេណទីតាំងទូរទស្សន៍ក្រុងព្រះសីហនុ ៤ នកំពស់ត្រឹម ២០ ម៉ែត្រ គត់ ។

ប្រការ ២ : រាល់ដំណើរការតម្លើងអង់តែននេះ ត្រូវគោរពតាមកិច្ចសន្យា និងតាមការឯកភាព ពីអាជ្ញាធរដែនដីមិនត្រូវប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គមនិងត្រូវគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងពត៌មាន មន្ទីរពត៌មាន ក្រុងព្រះសីហនុ និងខេត្តកំពត និងអាជ្ញាធរដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

ភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៣៩/៩៧ ព.មប្រក

រដ្ឋមន្ត្រីក្រសួងពត៌មាន

****

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រម នស.រកម ចុះថ្ងៃទី ២៤-០១-៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន
- យោងលិខិតស្នើសុំរបស់ CHRISTANE BLANCOT ជាស្ថា[illegible]ាតិបារាំងចុះថ្ងៃទី ២៩-៤-៩៧
- យោងលិខិតស្នើសុំនាំចូលដោយរួចពន្ធនូវសៀវភៅដែលជាស្នាដៃ និពន្ធរប.ស់ក្រសួងវប្បធម៌បារាំង និងក្រុមការងាររៀបចំទីក្រុងប៉ារីស ចុះថ្ងៃទី ២៩-៥-៩៧ របស់ក្រសួងពតិមាន ។

សម្រេច

ប្រការ ១ : អនុញ្ញាតជូនលោក DULAC នាំចូលនិងចែកផ្សាយសៀវភៅ ដែលមាន ចំណងជើង PHNOM PENH DEVELOPPEMENT URBAIN ET PATRIMOINE នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : រាល់ដំណើរការនាំចូលនិងចែកផ្សាយសៀវភៅ ទាំងអស់នោះត្រូវអនុវត្តតាមច្បាប់ដើមនៃសៀវភៅដែលបានតម្កល់ទុកនៅក្រសួងពតិមាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍នៃ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងពតិមាន មន្ទីរពតិមានគ្រប់ខេត្ត និងអាជ្ញាធរដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

ភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៤១ /៩៧ ព ម ប្រក

រដ្ឋមន្ត្រីក្រសួងពតិមាន

****

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម ចុះថ្ងៃទី ២៤-០១-៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន
- យោងលិខិតសំណើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ព «ម៉េង ហាវ» ចុះថ្ងៃទី ២០-៥-១៩៩៧ របស់លោក ឃុន ម៉េងហាវ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **ឃុន ម៉េងហាវ** សញ្ជាតិកម្ពុជា ទីលំនៅបច្ចុប្បន្នស្ថិតនៅ ផ្ទះលេខ ៨១ អឺ០ ផ្លូវលេខ ១៧០ សង្កាត់ ជ័យជំនះ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ «ម៉េង ហាវ» មានទីតាំងស្ថិតនៅដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវគោរពតាមកិច្ចសន្យា សមស្របតាមទំនៀមទំលាប់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍នៃ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងពតិមាន និងប្រធានមន្ទីរពតិមាន រាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

ភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ១៩៩៧

ប្រកាសលេខ ១៤២/៩៨ ពមប្រក

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

– បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន សរកម ០៨៩៤–០៧ ចុះថ្ងៃទី ០១ កញ្ញា ឆ្នាំ ១៩៩៥ ។

– បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ០០៨/៩៥ ពម ចុះថ្ងៃទី ០៤ មករា ឆ្នាំ១៩៩៥ ស្តីពីការអនុញ្ញាតអោយទស្សនាវដ្តីមូលមិត្តបោះពុម្ពចែកផ្សាយដោយមានលោក អ៊ិត សំហេង ជាចាងហ្វាងការផ្សាយ ។

– បានឃើញសំណើសុំផ្សាយបន្ថែមរបស់ទស្សនាវដ្តី «មូលមិត្ត» ដែលដាក់ពីលើព្រឹត្តិប័ត្រប្រចាំថ្ងៃឈ្មោះភ្នំពេញដេលី PHNOM PENH DAILY ជាភាសាខ្មែរអង់គ្លេស និងបារាំង ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយចេញផ្សាយបន្ថែមព្រឹត្តិប័ត្រ ភ្នំពេញដេលី PHNOM PENH DAILY ជាភាសាខ្មែរ អង់គ្លេស និងបារាំង ដែលជាផ្នែក នៃ ទស្សនាវដ្តីមូលមិត្តដោយមានលោកស្រី តាន់ សុវណ្ណឌី ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកសារពត៌មាន ច្បាប់ស្តីពីរបបសារពត៌មាននិងច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ ត្រូវប្រគល់ព្រឹត្តិប័ត្រចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកដំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស នឹងសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួនត្រូវទទួល ទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងចាងហ្វាងការផ្សាយព្រឹត្តិប័ត្រ ភ្នំពេញដេលី PHNOM PENH DAILY ត្រូវអនុវត្តប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ខៀវ កាញារីទ្ធ

* * *

៣_ នីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

ប្រកាស

ភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៨ ស.កសខ
កែសំរួលស្តីពី ផែនការគ្រប់ដណ្តប់សុខាភិបាល ខេត្ត រតនគីរី

* * *

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ ១១ ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រម នស រកម ០១៩៦ ៣០ ចុះថ្ងៃទី ២៤ ខែ ០១ ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញសារាចរលេខ ៨៥ ស កកទ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងសុខាភិបាលស្តីពីការកសាង និង ការអនុវត្តន៍ផែនការគ្របដណ្តប់សុខាភិបាលស្រុក ឃុំ ។
- យោងតាមកំណត់ផែនការគ្របដណ្តប់លេខ ៦០៥ លអខ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៦ របស់ខេត្ត រតនៈគិរី
- យោងតាម ប្រកាសលេខ ៣៣១ ស កសផ ចុះថ្ងៃទី ២៤ ខែ ៧ ឆ្នាំ ១៩៩៦ ស្តីពីផែនការគ្រប ដណ្តប់សុខាភិបាល ខេត្ត រតនៈគិរី ។
- យោងលិខិតលេខ ៥៨/៩៧ ស ខររ ចុះថ្ងៃទី ១០ ខែ ០២ ឆ្នាំ ១៩៩៧ របស់មន្ទីរសុខាភិបាលខេត្តរតនៈគិរី ស្តីពីសំណើសុំបង្កើតបន្ថែមមណ្ឌលសុខភាពមួយកន្លែងក្នុងស្រុកបានលុង លើផែនការគ្របដណ្តប់សុខាភិបាលខេត្ត ឆ្នាំ ១៩៩៥
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង ។

សំរេច

ស្រុកប្រតិបត្តិដែលមានចែងក្នុងប្រការ១ នៃប្រកាសលេខ ៣៣១ ស កសផ ចុះថ្ងៃទី ២៤ ខែ ០៧ ឆ្នាំ ១៩៩៦ត្រូវបានកែប្រែដូចតទៅ :

ប្រការ ១ ថ្មី : ស្រុកប្រតិបត្តិដែលទទួលខុសត្រូវដោយមន្ទីរពេទ្យខេត្តរតនៈគិរី ត្រូវគ្របដណ្តប់មណ្ឌលសុខភាពចំនួន ១៦ ។ មណ្ឌលសុខភាពមួយដែលបន្ថែមលើផែនការគ្របដណ្តប់ ឆ្នាំ ១៩៩៥ គឺមណ្ឌលសុខភាពក្នុងស្រុកបានលុង ។ ខ្លឹមសារដទៃទៀត នៃប្រកាសលេខ ៣៣១ ចុះថ្ងៃទី ២៤ ខែ ៧ ឆ្នាំ ១៩៩៦ ដូចយោងខាងលើរក្សាទុកនៅដដែល ។

ប្រការ ២ : ខុទ្ទកាល័យក្រសួងសុខាភិបាល នាយកដ្ឋានសុខាភិបាល និង មន្ទីរសុខាភិបាលខេត្តរតនៈគិរី ត្រូវទទួលបន្ទុកអនុវត្តអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃ ដែលបានចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
វេជ្ជ. ឈា ម៉ាង

៤_ នីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

ភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤២២ អយក ប្រក
ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគណិតវិទ្យា
សំរាប់គ្រូថ្នាក់ទី ២

****

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតីចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤–៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជននិង កីឡា
- បានឃើញលិខិតឧទ្ទេសនាម លេខ ៣១៨ អយក ឧទន ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈ កម្មការរៀបចំប្រព័ន្ធអប់រំ

- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅគណិតវិទ្យាសំរាប់គ្រូថ្នាក់ទី ២ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅគណិតវិទ្យាសំរាប់គ្រូថ្នាក់ទី ២ ដែលជាស្នាដៃនិពន្ធ របស់ គណៈកម្មការគណិតវិទ្យាបឋមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំយុវជន និងកីឡា និង រៀបរៀងដោយលោក **ចាន់ ថន** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំនេះទូទៅ និងមន្ត្រីយសិក្សាមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៥_ ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

ភ្នំពេញ, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៧

សេចក្តីសម្រេចលេខ ១១៤/៩៧គធស

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

*****

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស/រកម ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ ឆ្នាំ ១៩៩៦ ។
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំនិង ប្រព្រឹត្តិទៅ នៃ ក្រសួងធម្មការ និងសាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយ ប្រូតេស្តង់ ក្រុមសាវ័កថ្មី របស់លោក សីន សៅ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តមអភិបាលខេត្ត កំពត លេខ ៨៤ លច.ប កព ៩៧ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រីស្តនិកាយប្រូតេស្តង់ ក្រុមសាវ័កថ្មី ឈ្មោះហៅថា សាវ័កថ្មីភូមិដំណាក់ទ្រព្យ មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្ទះលេខ ០៩ ផ្លូវ ០៣ ឃុំ ក្រាំងស្វាយ ស្រុក ឈូក ខេត្ត កំពត ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រីស្ត នៃ ព្រះវិហារឈ្មោះ សាវ័កថ្មី ភូមិដំណាក់ទ្រព្យ ត្រូវអនុញ្ញាតអោយប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រីស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ សាវ័កថ្មី ភូមិដំណាក់ទ្រព្យ ត្រូវគោរពនិងអនុវត្តន៍អោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំ នៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយ ដែលផ្ទុយអំពី សេចក្តីសម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និង សាសនា ខេត្ត ក្រុង និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសម្រេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

រដ្ឋលេខាធិការ

ហៀង ចណ្ណារិទ្ធ

* * *

ភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១១៥/៩៧ កធស

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

*****

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះ រាជក្រមលេខ នស/រកម ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។

- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ០០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅ នៃ ក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយ ប្រូតេស្តង់ គ្រុមសារីកច្ឆិរបស់លោក **ម៉ាស់ អ៊ឹម** ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៧ ។
- បានឃើញចំណារបញ្ជូនរបស់ ឯកឧត្តម អភិបាល ខេត្ត ពោធិសាត់ លេខ ៣៣៥ ពស ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៧ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូលតេស្តង់គ្រុមសារីកគ្គី ឈ្មោះ ហៅថា សារីកច្ឆិ អូរស្តៅ មួយកន្លែង ដែលមានទីតាំងស្ថិតនៅ ឃុំ ស្វាយអាត់ ស្រុក ស័ក្រាមាស ខេត្ត ពោធិសាត ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃព្រះវិហារឈ្មោះ សារីកច្ឆិ អូរស្តៅ ត្រូវអនុញ្ញាតអោយប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនា សុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ សារីកច្ឆិ អូរស្តៅ ត្រូវគោរពនិងអនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជានិងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំ នៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ ទាំងឡាយណាដែលផ្ទុយអំពី សេចក្តីសម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ នឹង សាសនា ខេត្ត ពោធិសាត់ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសម្រេចនេះអោយមានសិទ្ធភាពខ្ពស់។

ប្រការ ៥ : សេចក្តីសម្រេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ទណ្ឌរ័ត្ន

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល